# របាយការណ៍ស្តីពីការត្រួតពិនិត្យបរិស្ថាន និងសង្គម
# ក្រុមហ៊ុនប្រេ្កនឌីស ធីមបើរ អិលធីឌី

## ១. សេចក្តីផ្តើម

ក្រុមហ៊ុនប្រេ្កនឌីស ធីមបើរ អិលធីឌី គឺជាក្រុមហ៊ុនបរទេស ទទួលបានថវិការវិនិយោគពីប្រទេសដាណាម៉ាក់។ ក្រុមហ៊ុននេះ បានទទួលសិទ្ធិស្របច្បាប់សម្រាប់ការវិនិយោគ លើការដាំឈើម៉ៃសាក់ពីរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩។ តាមរយៈកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ក្រុមហ៊ុនបានចាប់ផ្តើមអនុវត្តការងារប្រតិបត្តិរបស់ខ្លួលើដីសម្បទានសេដ្ឋកិច្ច ស្ថិតនៅក្នុងឃុំពីរគឺ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច និងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ លើផ្ទៃដីសរុបចំនួន ៩.៨២០ហិកតា។

តាមរយៈគោលនយោបាយស្តីពីទំនួលខុសត្រូវសង្គម និងវិញ្ញាបនប័ត្របញ្ជាក់ពីការគ្រប់គ្រងព្រៃឈើបានល្អ (FSC) ក្រុមហ៊ុនចាំបាច់ត្រូវយកចិត្តទុកដាក់លើការគាំពារបរិស្ថាន និងសង្គមនៅក្នុងដំណើរការអនុវត្តគម្រោ ដែលជាផ្លូវដ៏ត្រឹមត្រូវមួយដើម្បីបញ្ជាក់ថាក្រុមហ៊ុនគោរពទៅតាមច្បាប់ និងលិខិតបទដ្ឋានរបស់ព្រះរាជាណាចក្រកម្ពុជា។ ដូចច្នេះ ការគ្រប់គ្រងបិរស្ថាន និងការទទួលខុសត្រូវចំពោះសង្គម ត្រូវបានយកមកគិតគូរ ដោយអនុឡោមទៅតាមកិច្ចសន្យាការពារបរិស្ថាន ច្បាប់ស្តីពីការគ្រប់គ្រងបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹតស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គមជាមួយក្រសួងបរិស្ថាន។ នៅក្នុងកិច្ចសន្យាការពារបរិស្ថាន ក្រុមហ៊ុនបានឯកភាពផ្តល់របាយការណ៍រៀងរាល់បីខែម្តងស្តីពីការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។ ផែនការនេះ ត្រូវបានប្រើប្រាស់ជាឯកសារគោលក្នុងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលអាចកើតមានឡើងដោយយថាហេតុ ពេលមុនអនុវត្ត អំឡុងពេលអនុវត្ត និងក្រោយពេលអនុវត្តគម្រោង។ នៅក្នុងផែនការគ្រប់គ្រងបរិស្ថានបានកំណត់នូវសូចនករសំខាន់ៗមួយចំនួនសម្រាប់ធ្វើការវាយតម្លៃផលប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមនៅក្នុងតំបន់។ ប៉ារ៉ាម៉ែត្រ ដែលបានបញ្ជាក់ក្នុងកិច្ចសន្យា ក៏ត្រូវបានយកមកដាក់បញ្ចូលដើម្បីធ្វើការផ្ទៀងផ្ទាត់ផងដែរ។

ដូននេះ របាយការាណ៍ស្តីពីលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជាក់ពីការតាំងចិត្ត ឬឆន្ទៈក្នុងការការពារបរិស្ថាន ដើម្បីបញ្ជាសផលប៉ះពាល់ឲ្យនៅក្នុងកំរិតអប្បរមា នៅពេលការអនុវត្តការងារឈូសឆាយ និងរៀបចំចម្ការឈើម៉ៃសាក់ជាដើម។ លើសពីនេះទៀត វាក៏ជាឯកសារមួយសម្រាប់ស្ថានប័នមានសមត្ថកិច្ចក្នុងការផ្តល់យោបល់កែលម្អរមកដល់ក្រុមហ៊ុនដែលកំពង់អនុវត្តគម្រោង។ បាយការណ៍នេះ នឹងដាក់ជូននាយកដ្ឋានអង្កេត ត្រួតពិនិត្យ និងវាយតម្លៃហេតុផលប៉ះពាលបរិស្ថាន និងសង្គម នៃក្រសួងបរិស្ថានដើម្បីពិនិត្យតាមការគួរ។

### ១.១ គោលបំណង

ការត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន មានគោលបំណងសំខាន់ៗដូចខាងក្រោមៈ

- ដើម្បីកំណត់ពីផលប៉ះពាល់សំខាន់ៗដែលអាចនឹងកើតមានឡើងនៅក្នុងការអនុវត្តគម្រោង
- បង្កើតកម្មវិធីការពារ ដើម្បីកាត់បន្ថយផលប៉ះពាល់ឲ្យនៅត្រឹមកម្រិតអប្បរមា
- ដើម្បីធានាថា ការអនុវត្តគម្រោង និងការថែទាំចម្ការឈើ បានអនុឡោមទៅតាមផែនការគ្រប់គ្រងបរិស្ថាន និងសង្គម

## ២. វិធីសាស្រ្តនៃការវាយតម្លៃ

ការអង្កេតនៅលើទីវាលត្រូវបានប្រើប្រាស់នៅក្នុងការកំណត់នូវផលប៉ះពាល់អវិជ្ជមាន នៅតាមទីតាំងនៃការអនុវត្តការងារ ដូចជា ទីតាំងសាងសង់ផ្លូវ, ជួសជុលផ្លូវចាស់, ទីតាំងសំអាតស្មៅ ឬរុក្ខជាតិចង្រៃ, ទីតាំងដាំឈើថ្មី,

តំបន់បានឈូសឆាយដីថ្មី និងតំបន់អភិរក្ស (តំបន់ការពារប្រភពទឹក និងភ្នំ) ជាដើម។ លើសពីនេះទៀត រោងជាង, ឃ្លាំងប្រេង, ថ្នាលបណ្តុះកូនឈើ និងការិយាល័យបុគ្គលិក ក៏ត្រូវបានពិនិត្យ និងវាយតម្លៃផងដែរ ថាតើមានការលេចជ្រាបប្រេង ឬប្រេងម៉ាស៊ីន និងការគ្រប់គ្រងកាកសំណល់រឹងបានត្រឹមត្រូវកម្រិតណា។ កម្មករ និងបុគ្គលិកក្រុមហ៊ុនត្រូវបានជ្រើសរើសដោយចៃដន្យ សម្រាប់ធ្វើការសំភាសន៍ ដោយប្រើប្រាស់បញ្ជីសំណួរ (checklist)។ នៅក្នុងសំភាសន៍ និងការអង្កេតនៅទីវាល លើផ្នែកសំខាន់ៗមួយចំនួនដូចជា វិស្ថានរូបសាស្ត្រ, បរិស្ថានជីវៈសាស្ត្រ និងបរិស្ថានសង្គម ត្រូវបានធ្វើការផ្ទៀតផ្ទាត់។

## ៣. លទ្ធផលនៃវាយតម្លៃ

នៅក្នុងតារាងខាងក្រោមនេះ (តារាងទី១) គឺជាលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុនហ្វែនឌីស ធីមបើរ អិលធីឌី ក្នុងដំណាក់កាលអនុវត្តគម្រោងដាំឈើម៉ៃសាក់។

*តារាងទី១៖ លទ្ធផលនៃការវាយតម្លៃពីទីវាល*

| ល.រ | លក្ខណៈវិនិច្ឆ័យនៃការអង្កេត | លទ្ធផលនៃការអង្កេត |
|---|---|---|
| **ក.បរិស្ថានរូបសាស្ត្រ** | | |
| **១.ការហូរច្រោះ** | | |
| ១.១ | តើក្រុមហ៊ុនហ្វែនឌីស ភ្ជួរ និង ហែកដីក្នុងរដូវប្រាំងដែរឬទេ? | ការអនុវត្តការងាររបស់ក្រុមហ៊ុនដូចជា ការភ្ជួរដី ហែកដី ពូនរងដាំកូនឈើ ភាគច្រើនធ្វើឡើងនៅក្នុងរដូវប្រាំង។ មិនមានភស្តុតាង ឬការតវ៉ាណាមួយបញ្ជាក់ ពីការឈូសឆាយក្នុងរដូវវស្សា ត្រូវបានរកឃើញក្នុងអំឡុងពេលធ្វើការអង្កេតនៅទីវាលនោះទេ។ |
| ១.២ | តើការឈូសឆាយដី និងការអនុវត្តការងារប្រតិបត្តិបានបង្ករការហូរច្រោះដីដែរឬទេ? | ក្រុមហ៊ុនមិនបានធ្វើការឈូសឆាយនោះទេនៅក្នុងអំឡុងពេល ៣ ខែចុងក្រោយនេះ។ ការវាស់វែងលើការគ្រប់គ្រងបរិស្ថាននឹងបញ្ជាក់ក្នុងពេលក្រោយ ឬការវាយបន្ទាប់ទៀត។ |
| ១.៣ | តើការថែទាំការងារប្រតិបត្តិរបស់ក្រុមហ៊ុនហ្វែនឌីសបង្ករការហូរច្រោះដែរឬទេ? | គឺកតាងពីផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីការជួសជុលហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុមហ៊ុននោះទេ។ ក្រុមហ៊ុនបាននឹងកំពង់ ជម្រះស្មៅនៅតាមចម្ការឈើចាស់ ជួសជុលផ្លូវ និងធ្វើផ្លូវថ្មី ដែលសកម្មភាពទាំងអស់នេះត្រូវបានអនុទ្យោមតាមស្តង់ដានៃដំណើរការអនុវត្តការងារ (SOP) ។ ជាសរុប សកម្មភាពទាំងនេះមិនបានបង្ករឲ្យមានការហូរច្រោះដីនោះទេ។ |
| ១.៤ | តើផ្លូវថ្នល់ដែលក្រុមហ៊ុន កំពង់ប្រើ បានបង្ករឲ្យមានការហូរច្រោះដីដែរឬទេ? | ផ្លូវសំខាន់ៗ និងផ្លូវបន្ទាប់ត្រូវបានក្រាលគ្រួសក្រហម ដើម្បីងាយស្រួលធ្វើដំណើរ និងការពារការហូរច្រោះ ដែលអាចកើតមានឡើងនៅពេលមានភ្លៀងធ្លាក់ជោគជាំ។ លើសពីនេះទៀត ផ្លូវទាំងអស់ត្រូវបានត្រួតពិនិត្យ និងធ្វើការជួសជុលជារៀងរាល់ឆ្នាំ។ មិនមានផលប៉ះពាល់ណាមួយបានរកឃើញក្នុងអំឡុងពេលនៃការវាយតម្លៃនេះទេ។ |
| ១.៥ | តើក្រុមហ៊ុនហ្វែនឌី បានឆ្លើយតបទៅនឹងការរក្សាទុក និង ការពារតំបន់ការពារប្រភពទឹកនៅសងខាង និងស្ទឹង | ក្រុមការងារប្រតិបត្តិរបស់ក្រុមហ៊ុន និងអ្នកទទួលការបន្ត ត្រូវបានណែនាំអំពីការរក្សាទុកនូវតំបន់ការពារប្រភពទឹក (៣០-៥០ម)នៅសងខាងស្ទឹង និងអូរនៅគ្រប់តំបន់, អនុតំបន់ទាំងអស់ ដោយហេតុថាក្រុមហ៊ុនត្រូវគោរពតាមកិច្ចសន្យាការពារបរិស្ថានជាមួយក្រសួងបរិស្ថាន។ មិនមានហេតុ |

| | | |
|---|---|---|
| | ដែរឬទេ? | ផលប៉ះពាល់ណាមួយគួរឲ្យកត់សំគាល់នោះទេ។ |
| ២.ប្រព័ន្ធជលសាស្ត្រ | | |
| ២.១ | តើក្រុមហ៊ុនប្រេ្គនឌីបានរក្សាប្រភពទឹកធម្មជាតិ និងទិសដៅទឹកហូរធម្មជាតិដែរឬទេ? | ក្រុមហ៊ុន បានរក្សាទិសដៅទឹកហូរតាមផ្លូវទឹកធម្មជាតិ ដោយដាក់លូរ និងធ្វើទំនប់បង្ហៀរទឹកនៅកន្លែងដែលមានផ្លូវឆ្លងកាត់។ កម្មករ បុគ្គលិករបស់ក្រុមហ៊ុនត្រូវបានធ្វើការណែនាំមិនឲ្យអ្នកណាម្នាក់ បង្ហាំងទឹក ឬបំផ្លាញផ្លូវទឹកធម្មជាតិនោះទេ។ មិនមានភស្តុតាងណាមួយបញ្ជាក់ពីការបំផ្លាញប្រភពទឹក ឬផ្លូវទឹកធម្មជាតិនៅក្នុងដីសម្បទានសេដ្ឋកិច្ចនេះទេ។ |
| ២.២ | តើមានការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិតដែរឬទេនៅក្នុងការងារប្រតិបត្តិរបស់ក្រុមហ៊ុនប្រេ្គនឌីស? បរិមាណ? ពេលវេលា? | ប្រភេទសារធាតុគីមីចំនួន៣ បាននឹងកំពង់ប្រើប្រាស់នៅក្នុងការអនុវត្តគម្រោងរបស់ក្រុមហ៊ុន គឺជី (N.P.K), ថ្នាំសម្លាប់ស្មៅ និងរុក្ខជាតិចង្រៃ (Glyposate) និងអកម៉ូនបណ្តុះឫស (IBA)។ ក្រុមហ៊ុនបានធ្វើការកត់ត្រាពីបរិមាណប្រើប្រាស់ ពេលវេលានៃការប្រើប្រាស់ក្នុងតារាងម៉ាទ្រិចដើម្បីធានាថាការប្រើប្រាស់ក្នុងកំរិតមួយអនុញ្ញាត្ត ដោយអនុឡោមតាម SOP 3007។ |
| ២.៣ | តើក្រុមហ៊ុនប្រេ្គនឌីសប្រើប្រាស់ទឹកក្រោមដីដែរឬទេ? | អណ្តូងដៃ ឬអណ្តូងស្នប់មិនបានឃើញមាននៅក្នុងដីសម្បទាននោះទេ។ ទឹកដែលប្រើប្រាស់សម្រាប់ការអនុវត្តគម្រោងសព្វថ្ងៃដូចជា កម្មករ និងបុគ្គលិកប្រើប្រាស់ ស្រោចស្រប់នៅក្នុងថ្នាលបណ្តុះកូនឈើ យកមកពីស្ទឹងនៅក្រៅតំបន់ដីសម្បទាន។ |
| ២.៤ | តើក្រុមហ៊ុនប្រេ្គនឌី បានពិនិត្យគុណភាពទឹក (ទឹកបរិភោគ និងទឹកស្ទឹង) ដែរឬទេ? | ការប្រមូលសំណាកទឹក សម្រាប់ធ្វើការវិភាគពីគុណភាពទឹកត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីបង្ហាញឲ្យឃើញថា ទឹកនៅតាមប្រភពទឹក និងទឹកដែលផ្តល់ជូនកម្មករ និងបុគ្គលិកសម្រាប់បរិភោគមិនមានការបំពុលដោយធៀបនឹងស្តង់ដារទឹកអាចបរិភោគបាន។ មកដល់ពេលនេះ ការប្រមូលសំណាកទឹកបានបញ្ចប់ និងស្ថិតនៅតំណាក់កាលវិភាគនៅមន្ទីរពិសោធន៍នៅឡើយ។ លទ្ធផលវិភាគគុណភាពទឹកនឹងផ្តល់ជូននៅក្នុងរបាយការណ៍បន្ទាប់។ |
| ៣. សំលេង និងរំញ័រ | | |
| ៣.១ | តើក្រុមប្រេ្គនឌីស មានការចល័តការងារនៅពេលយប់ដែរឬទេ? | ការអនុវត្តការប្រតិបត្តិ ត្រូវបានកំណត់តែពេលថ្ងៃប៉ុន្នោះ ហើយការចល័តគ្រឿងចក្រ ឬការងារនៅពេលយប់មិនមានការលើកឡើងនោះទេក្នុងអំឡុងពេលសំភាសន៍ជាមួយកម្មករ និងបុគ្គលិកនៅទីវាល។ |
| ៣.២ | តើការងារប្រតិបត្តិដែលមានសំលេងរំខានត្រូវបានអនុវត្តនៅពេលថ្ងៃដែរឬទេ? | រណាយន្តត្រូវបានប្រើប្រាស់ក្នុងការក្រៃមែកឈើ ឬធ្វើរហាលចម្ការឈើដែលអនុញ្ញាត្តឲ្យធ្វើតែក្នុងអំឡុងពេលថ្ងៃតែប៉ុន្នោះ។ បុគ្គលិកដែលត្រូវបត្រូវបានផ្តល់ការបណ្តុះបណ្តាលពីសុវត្ថិភាពក្នុងការប្រើប្រាស់ និងរបៀបប្រើប្រាស់ជាមុន។ ឧបករណ៍ការពារត្រចៀក, ស្បែកជើងកវែង និងសំលៀកបំពាក់ ត្រូវបានផ្តល់ជូន និងការពិនិត្យដោយ QC។ |

| | | |
|---|---|---|
| ៣.៣ | តើការអនុវត្តការងារប្រតិបត្តិរបស់ក្រុមហ៊ុន តម្រូវឲ្យការគ្រប់គ្រងធូលីដែរឬទេ? បើមានតម្រូវការ តើក្រុមហ៊ុនបានអនុវត្តដែរឬទេ? | ការអនុវត្តការងារប្រតិបត្តិ មិនតម្រូវឲ្យមានការគ្រប់គ្រងធូលីនោះទេ ព្រោះថាមានប្រជាជនរស់តិចតួចបំផុតនៅសងខាងផ្លូវ ហើយការងារភាគច្រើននៅឆ្ងាយពីភូមិស្ថានប្រជាជន (ក្នុងព្រៃ)។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនបានកំណត់ល្បឿនតែ ៤០ គ.ម/ម៉ោង ក្នុងបើកក្នុងដីសម្បទាន ឬកន្លែងដែលមានផ្ទះប្រជាជននៅសងខាងផ្លូវ។ ដូចនេះ មិនចាំបាច់ត្រូវស្រោចទឹកផ្លូងនោះទេក្នុងដំណាក់នេះ។ |
| ៤.ការគ្រប់កាកសំណល់រឹង រាវ | | |
| ៤.១ | តើក្រុមហ៊ុនហ្គ្រេនឌីគ្រប់គ្រងកាកសំណល់យ៉ាងដូចម្តេច? | កាកសំណល់ទាំងអស់ត្រូវបានប្រមូលដាក់មួយកន្លែងរួចកប់ឬដុតចោលនៅកន្លែងដែលមានសុវត្ថិភាព។ ក្រុមហ៊ុនរក្សាកាកសំណល់នៅទីតាំងមានរយៈកំពស់ខ្ពស់ជាងនីវ៉ូទឹក ដើម្បីចៀសវាងការលេចធ្លាយដោយចៃដន្យ។ បុគ្គលិកទាំងអស់ មានការទទួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រងកាកសំណល់ អនុឡោមតាមបទបញ្ញាស្តីពីទីតាំងស្អាតរបស់ក្រុមហ៊ុន។ |
| ៤.២ | តើក្រុមហ៊ុនមានការគ្រប់គ្រងប្រេងសាំង ឬម៉ាស៊ូត, សារធាតុរលាយក្នុងទឹក និងប្រេងម៉ាស៊ីនបានត្រឹមត្រូវដែរឬទេ (ជាសវាងការបោះចោលធុងប្រេង ឬប្រេងម៉ាស៊ីនទៅក្នុងប្រភពទឹក)? | គ្រឿងយន្ត និងម៉ាស៊ីនទាំងអស់មានត្រួតពិនិត្យជាប្រចាំ និងរាយការណ៍ក្នុងករណីមានលេចធ្លាយប្រេង ឬប្រេងម៉ាស៊ីន។ លើសពីនេះទៀត តំរ៉ងប្រេងស្រក់ត្រូវបានគេប្រើប្រាស់ដាក់ក្រោមគ្រឿងម៉ាស៊ីន នៅពេលធ្វើចត ឬជួសជុលនៅក្នុងរោងជាងដើម្បីការពារការលេចជ្រាបដោយចៃដន្យ។ មិនមានធុងប្រេង ឬប្រេងម៉ាស៊ីនបានរកឃើញនៅហាលថ្ងៃ ឬបោះចោលក្នុងប្រភពទឹកនោះទេ។ |
| ៤.៣ | តើទីតាំងឃ្លាំងប្រេង និងរោងជាងស្ថិតនៅតំបន់ខ្ពស់ជាងកម្រិតទឹកជន់លិចនៅរដូវវស្សាដែរឬទេ? | ឃ្លាំងប្រេង និងរោងជាង គឺស្ថិតលើទីទួលខ្ពស់ និងមានចំងាយឆាយពីប្រភពទឹក។ ការលេចធ្លាយប្រេង ឬប្រេងម៉ាស៊ីនដោយចៃដន្យ មិនអាចហូរចូលទៅក្នុងស្ទឹង ឬអូរបានទេ ព្រោះក្រុមហ៊ុនបានកសាងរបាំងទឹកកខ្វក់ ឬអាងស្តុកកាកសំណល់រាវ ដែលអាចកើតមានឡើងនៅតំបន់ជុំវិញឃ្លាំងប្រេង និងរោងជាង។ |
| **ខ. បរិស្ថានរូបសាស្រ្ត** | | |
| ១.ព្រៃឈើ | | |
| ១.១ | តើក្រុមហ៊ុនហ្គ្រេនឌីសបានរក្សាតំបន់ទ្រនាប់អូរ ឬស្ទឹង (៣០-៥០ម) ដែរឬទេ? | សូមមើលចំណុច ១.៤ ផ្នែក "**ក**" |
| ២. | សត្វព្រៃ | |
| ២.១ | តើក្រុមហ៊ុនហ្គ្រេនឌីស បានធ្វើការផ្សព្វផ្សាយ ពីការហាមឃាត់ការបរបាញ់ និងការធ្វើអាជីវកម្មសត្វព្រៃដែរឬទេ? | បុគ្គលិក និងកម្មកររបស់ក្រុមហ៊ុនត្រូវបានផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីការហាមឃាត់ការបរបាញ់ និងជួញដូរសត្វព្រៃ។ បច្ចុប្បន្ន ក្រុមហ៊ុនបានពង្រាងផែនការអភិរក្ស ដែលបានដាក់បញ្ចូលនូវសកម្មភាពសំខាន់ៗក្នុងកិច្ចការពារជីវៈចម្រុះ។ លើសពីនេះទៀត ផ្ទាំងរូបភាពអប់រំស្តីពីការអភិរក្សជីវៈចម្រុះ ត្រូវបានដាក់តាមចំណុច |

| | | |
|---|---|---|
| | | សំខាន់មួយចំនួនដើម្បីផ្សព្វផ្សាយដល់សហគមន៍មូល ពីអ្វីដែលពួកគាត់គួរធ្វើ និងមិនគួរធ្វើ។ |
| ២.២ | តើក្រុមហ៊ុនហ្វ្រេនឌីស បានរក្សាដើមឈើធំៗ ឬដើមឈើងាប់សម្រាប់ជាជម្រកសត្វ និងកន្លែងពងកូនរបស់សត្វព្រៃដែរឬទេ? ក្នុងករណីមានសុវត្ថិភាព? | ក្រុមហ៊ុនកាត់ឆ្ការដីព្រៃដែលនៅតាមដងអូរ និងស្ទឹងចេញពីដីដែលត្រូវនឹងត្រូវឈូសឆាយសម្រាប់ជាជម្រក និងជាច្រកល្មៀងសត្វព្រៃនៅក្នុងដីសម្បទានរបស់ខ្លួន។ ព្រៃរក្សាទុកប្រមាណជា ៣០-៥០ម នៅតាមមាត់អូរ ឬស្ទឹង (សងខាពី ៦០ ទៅ ១០០ម) ជាតំបន់ការពារប្រភពទឹក ដោយសមល្មមអាចសត្វព្រៃឆ្លងកាត់ទៅតំបន់អភិរក្សនៅភាគខាងត្បូងនៃដីសម្បទាន។ មិនមានដើមឈើធំៗនៅសេសសល់ឡើយព្រោះថាជាព្រៃរិចរិលខ្លាំង ហើយដើមឈើងាប់មិនអាចរក្សាទុកបាននោះទេ ព្រោះអាចបង្ករគ្រោះថ្នាក់ដល់កម្មករ និងដើមម៉ែសាក់នៅពេលមានខ្យល់ខ្លាំងម្តងៗ។ |
| ២.៣ | តើក្រុមហ៊ុនហ្វ្រេនឌីស បានរក្សាទុកតំបន់ច្រកល្មៀងសត្វ និងតំបន់អភិរក្សដែរឬទេ? | ក្រុមហ៊ុនទទួលខុសត្រូវចំពោះកិច្ចការពារតំបន់អភិរក្ស ដែលក្នុងនោះរួមបញ្ចូលទាំងតំបន់ការពារប្រភពទឹកនៅតាមសងខាងមាត់អូរ និងស្ទឹងផងដែរ។ តំបន់ការពារប្រភពទឹក, តំបន់ដីសើម, ព្រៃស្រោង, ព្រៃពាក់កណ្តាលស្រោង ត្រូវបានកាត់ចេញពីដីដាំឈើរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនមិនត្រូវបានអនុញ្ញាតឲ្យអភិវឌ្ឍនៅតំបន់ទាំងនេះនោះទេ។ |
| ៣. | **វារីសាស្រ្ត** | |
| ៣.១ | តើក្រុមហហ៊ុនហ្វ្រេនឌីស បានរក្សាទុកតំបន់ការពារប្រភពទឹកសម្រាប់ជាជម្រកត្រី និងវារីជាតិដទៃទៀតដែរឬទេ។ | សូមមើចំណុច ១.៥ ផ្នែក "**ក**" |
| 3.2 | តើមានការនេសាទខុសច្បាប់ ( ឆក់ត្រី, នេសាទនៅរដូវត្រីពង..) កើតមាននៅក្នុងតំបន់សម្បទានដែរឬទេ? | ក្រុមហ៊ុនបានផ្តល់វគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់បុគ្គលិក កម្មករអំពីការហាមឃាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដូចជាឧបករណ៍ឆក់ត្រីជាដើម ហើយក្រុមហ៊ុនមិនអនុញ្ញាតឲ្យប្រព្រឹត្តនៅក្នុងតំបន់សម្បទាននោះទេ។ តាមរយៈការសំភាសន៍សន្តិសុខក្រុមហ៊ុន និងប្រជាជនបានបញ្ជាក់ថា គេមិនដែលឃើញមានការនេសាទខុសច្បាប់កើតមានឡើងនោះទេ។ |
| **គ. បរិស្ថានសង្គម និងសេដ្ឋកិច្ច** | | |
| **១.កម្មសិទ្ធិដីធ្លី** | | |
| ១.១ | តើក្រុមហ៊ុនហ្វ្រេនឌីស បានគោរពសិទ្ធិកាន់កាប់ដីរបស់ប្រជាជននៅក្នុង ឬនៅក្បែរដីសម្បទានដែរឬទេ? | ក្បាលដីអាស្រ័យផល និងដីភូមិស្ថានរបស់ប្រជាជនជាច្រើនត្រូវបានឃើញមានវត្តមាននៅក្នុងតំបន់សម្បទានសេដ្ឋកិច្ចនេះ។ ក្បាលដីទាំងនេះ គឺពិតជាកម្មសិទ្ធិរបស់ប្រជាជន តាមរយៈកាត់ចេញដោយក្រុមហ៊ុន, ការវាស់វែងដោយក្រុមនិស្សិត និងការវាស់វែងរបស់សុរិយោដីក្នុងដំណើរការវាលតំលៃក្បាលសម្រាប់ចុះបញ្ជីដីរដ្ឋ។ |

| | | |
|---|---|---|
| ១.២ | តើក្រុមហ៊ុនមានទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ (ថ្នាក់ជាតិ, ខេត្ត, ស្រុក, ឃុំ និងភូមិ) ដែរឬទេ? | ក្រុមហ៊ុនតែងតែសហការណ៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងដំណើរការដោះស្រាយបញ្ហាដែលកើតមានឡើង និងពិភាក្សារកដំណោះស្រាយនានា។ ក្រុមហ៊ុនបានធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង (៣ខែ, ៦ខែ, ៩ខែ និងប្រចាំឆ្នាំ) ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពពាក់ព័ន្ធនានា (មន្ទីរកសិកម្ម, នាយកដ្ឋានផែនការ និងស្ថិតិ (ក.ស.ក), នាយកដ្ឋានកសិឧស្សាហកម្ម (ក.ស.ក), រដ្ឋបាលព្រៃឈើ, សាលាខេត្ត និងធ្វើរបាយការណ៍អនុវត្តផែនការគ្រប់គ្រងបរិស្ថានជូនក្រសួងបរិស្ថាន រៀងរាល់បីខែម្តងថែមទៀត។ ក្រុមហ៊ុនតែងតែឆ្លើយតបយ៉ាងទាន់ពេលវេលាចំពោះ ការណែនាំរបស់រដ្ឋាភិបាល, សេចក្តីជូនដំណឹង និងច្បាប់នានាដែលពាក់ព័ន្ធ។ បុគ្គលិកក្រុមហ៊ុន ដែលទទួលខុសត្រូវលើការងារទំនាក់ទំនងតែងជួបពិភាក្សាជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្វែងដំណោះស្រាយ និងកិច្ចសហការណ៍។ លើសពីនេះទៀត រាល់តវ៉ាទាំងពាក្យសំដីក្តី ទាំងលាយលក្ខណ៍អក្សរក្តី ក្រុមហ៊ុនតែងតែធ្វើការឆ្លើយតបដើម្បីជៀសវាងការភាន់ច្រឡំព័ត៌មានផ្សេងៗ។ |
| **២. ឱកាសការងារ** | | |
| ២.១ | តើក្រុមហ៊ុនបានផ្តល់ឱកាសការដល់ប្រជាជនដែលរស់នៅក្នុង ឬក្បែរតំបន់សម្បទាន ទៅតាមចំណេះដឹង បទពិសោធន៍ និងជំនាញដែរឬទេ? | ក្រុមហ៊ុនតែងធ្វើការផ្សព្វផ្សាយទៅដល់ប្រជាជននៅតំបន់ជុំវិញ និងនៅក្នុងតំបន់សម្បទាន តាមរយៈមេភូមិ មេឃុំ នៅពេលដែលក្រុមហ៊ុនមានតម្រូវការកម្មករ ឬជ្រើសរើសបុគ្គលិកនៅក្នុងតំបន់។ ប្រជាជន គឺមានភាពស្មើភាពគ្នាក្នុងការទទួលបានការងារ តាមរយៈការមកដាក់ពាក្យនៅការិយាល័យប្រចាំតំបន់របស់ក្រុមហ៊ុន។ បច្ចុប្បន្ននេះ ក្រុមហ៊ុនបានផ្តល់ការងារជាច្រើនដល់សហគមន៍មូលដ្ឋាន តាមជំនាញ ចំណេះដឹង និងបទពិសោធន៍របស់ពួកគេ។ លើសពីនេះទៀត ក្រុមហ៊ុនបានគាំទ្រអាជីវកម្មក្នុងស្រុកតាមរយៈការទិញសម្ភារៈផ្សេងៗ។ |
| ២.២ | តើក្រុមហ៊ុនហ្វ្រេនឌីស បានផ្តល់ចំណេះដឹង បច្ចេកទេស និងចែកកូនឈើជូនប្រជាជន ដែលចង់ដាំដុះដែរឬទេ? | ក្រុមហ៊ុនបានធ្វើការផ្សព្វផ្សាយជាសាធារណៈ តាមរយៈការប្រជុំផ្សព្វផ្សាយ តាមមេភូមិ មេឃុំថា ក្រុមមានគម្រោងចែកជូនកូនឈើប្រភេទម៉ៃសាក់ដល់ប្រជាជន ដែលមានបំណងចង់ដាំដុះ។ ប៉ុន្តែ មកដល់ពេលនេះ មិនទាន់មានប្រជាជនណាម្នាក់ចាប់អារម្មណ៍ដាំឈើនៅឡើយទេ។ |

## ៣. ការគំរាមកំហែង និងដំណោះស្រាយ

ដូចបានបញ្ជាក់នៅក្នុងតារាងលទ្ធផលនៃការវាយតម្លៃនៅលើទីវាល (តារាងទី១) ក្រុមហ៊ុនហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី បានអនុវត្តគម្រោងវិនិយោគ ដោយយកចិត្តទុកដាក់លើការការពារបរិស្ថាន និងសង្គម។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននូវមានចំណុចខ្វះខាតបន្តិចបន្តួច បានរកឃើញក្នុងពេលធ្វើការវាយតម្លៃ ដែលនឹងត្រូវ

ធ្វើការកែតម្រូវ ដោយអនុឡោមតាមសូចនករ ដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។ តារាងខាងក្រោម បង្ហាញពីចំណុចខ្វះខាត និងលទ្ធភាពដោះស្រាយក្នុងរយៈពេលខ្លី និងរយៈពេល (តារាងទី២)៖

*តារាងទី២៖ ការគំរាមកំហែង និងដំណោះស្រាយលើផលប៉ះពាល់បរិស្ថាន*

| ល.រ | កក្តាគំរាមកំហែងបរិស្ថាន | លទ្ធភាពក្នុងការដោះស្រាយ | |
|---|---|---|---|
| | | រយៈពេលខ្លី | រយៈពេលវែង |
| ១ | តំបន់ការពារប្រភពទឹកត្រូវភ្លើងឆេះ ដែលបង្ករការរាំងស្ទះយ៉ាងខ្លាំងដល់ការដុះលូតលាស់កូនឈើដោយធម្មជាតិ ឬបំផ្លាញកូនឈើជំនាន់ក្រោយ | • ពង្រឹងក្រុមល្បាតការពារភ្លើងឆេះព្រៃ<br>• បន្តផ្សព្វផ្សាយដល់សហគមន៍<br>• បង្កើនទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន<br>• ដាំឈើបន្ថែម | • រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ស្តារព្រៃឈើឡើងវិញតាមរយៈការជំរុញដំណុះធម្មជាតិ និងការដាំបន្ថែមនៅតំបន់រិចរឹលខ្លាំង<br>• ការពារភ្លើងឆេះព្រៃ |

ធ្វើនៅភ្នំពេញ, ថ្ងៃទី.........ខែ............ឆ្នាំ២០១៦

នាយកប្រតិបត្តិ

GRANDIS TIMBER LTD.

នីកូ ស្រ្តីដុម